ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ....៣៥៥៧....អពដ

GENERAL DEPARTMENT OF TAXATION

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៥

## សេចក្តីជូនដំណឹង
## រំលឹកស្តីពីការស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ

កន្លងមកអគ្គនាយកដ្ឋានពន្ធដារបានជូនដំណឹងស្តីពីការស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ លេខ ១៧២៦ អពដ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ ដល់ លោក-លោកស្រី ឬក្រុមហ៊ុន ដែលមានលក្ខណៈវិនិច្ឆ័យជាភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ ដែលមានបំណងប្រកបអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារ ឱ្យមកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ដើម្បីទទួលបានសិទ្ធិស្របច្បាប់ក្នុងការប្រកបអាជីវកម្ម។

ទោះបីជាមានការជូនដំណឹងនេះក៏ដោយ រហូតមកដល់ពេលនេះ អគ្គនាយកដ្ឋានពន្ធដារសង្កេតឃើញថា លោក-លោកស្រី ឬក្រុមហ៊ុន មួយចំនួនធំដែលកំពុងប្រកបអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារ នៅតែមិនទាន់បានយកចិត្តទុកដាក់មកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារតាមការជូនដំណឹងនេះនៅឡើយ។

អនុលោមតាមច្បាប់ស្តីពីសារពើពន្ធ និងប្រកាសលេខ ៤៥៥ សហវ.ប្រក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីភ្នាក់ងារសេវាកម្មពន្ធដារ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយស សូមជម្រាបជូនដំណឹងរំលឹកជាថ្មីម្តងទៀតដល់ លោក-លោកស្រី ឬក្រុមហ៊ុន ដែលកំពុងប្រកបអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ជ្រាបថា ចាប់ពី**ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦** តទៅ អគ្គនាយកដ្ឋានពន្ធដារនឹងមិនអនុញ្ញាតដល់ លោក-លោកស្រី ឬក្រុមហ៊ុន ឱ្យប្រកបអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារឡើយ។

ក្នុងករណី លោក-លោកស្រី ឬក្រុមហ៊ុននីតិបុគ្គល ឬក្រុមអាជីវកម្ម ប្រកបអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាប័ណ្ណ ត្រូវចាត់ទុកថាប្រព្រឹត្តអំពើរាំងស្ទះដូចមានចែងក្នុងមាត្រា១២៨ និងត្រូវទទួលរងការផ្តន្ទាទោសតាមមាត្រា ១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមនិងជឿជាក់ថា លោក-លោកស្រី និងក្រុមហ៊ុន ដែលមានលក្ខណៈវិនិច្ឆ័យជាភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ ដែលកំពុងប្រកបអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារដោយមិនទាន់មានអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ពិតជាយកចិត្តទុកដាក់និងរួសរាន់អញ្ជើញមកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណជាភ្នាក់ងារសេវាកម្មពន្ធដារ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

Collection by VCAT Professional Consultant